**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...៥៧៣......អ.ន.ក

ថ្ងៃព្រហស្បតិ៍ ១០កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុះ** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែមេសា ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំខែមេសា ឆ្នាំ២០១៨ មានដូចខាងក្រោមះ

## I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៤៨.៧៥៩ ហ.ត ស្មើនឹង១២៣,៦៨% នៃផែនការចំនួន ៤៤៣.៧០០ ហ.ត ច្រើនជាងឆ្នាំមុនចំនួន ៣០.០៣០ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៥៦១.០៦៩ ហ.ត តិចជាងឆ្នាំមុនចំនួន ៣.៣៧៤ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៥៤៨.៧៩២ ហ.ត ស្មើនឹង៩៧,៨១%
- ផ្ទៃដីសាបសរុប : ៤៧៩ ហ.ត តិចជាងឆ្នាំមុនចំនួន ៧៧ ហ.ត
- ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ : ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដី ៥៤៧.៨៥២ ហ.ត ស្មើនឹង៩៩,៨៣% នៃផ្ទៃដីអនុវត្ត ដែលទទួលបានទិន្នផលមធ្យម៤,៤៤៩ តោន/ហ.ត និងបរិមាណផលសរុប ២.៤៦៤.៧៣៥ តោន។







*ក្រាហ្វិកៈ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៤-២០១៨ គិតត្រឹម ចុងខែមេសា នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែមេសា ផ្ទៃដីភ្ជួររាស់រដូវប្រាំងឆ្នាំ២០១៨ មានចំនួនច្រើនជាងឆ្នាំ២០១៤ និងឆ្នាំ២០១៦ ប៉ុន្តែតិចជាងឆ្នាំ២០១៥ និងឆ្នាំ២០១៧។ ដោយឡែកការងារដាំដុះស្រូវរដូវប្រាំងឆ្នាំ២០១៨នេះ មានចំនួនច្រើនជាងបណ្តាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំចុងក្រោយ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ១២៧.២៣១ ហ.ត ច្រើនជាងឆ្នាំមុនចំនួន ២៦.០៤៧ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ១៧.២៧១ ហ.ត តិចជាងឆ្នាំមុនចំនួន ៦.០៥៥ ហ.ត។







ក្រាហ្វិក៖ ផ្ទៃដីដាំដុះដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងពីឆ្នាំ២០១៤-២០១៨ គិតត្រឹមចុងខែមេសា នៃឆ្នាំ

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមចុងខែមេសា ផ្ទៃដីដាំដុះដំណាំរួមផ្សំរដូវប្រាំងឆ្នាំ២០១៨ មានចំនួនច្រើនជាងគេ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំចុងក្រោយ។ ដោយឡែក ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរដូវប្រាំង ឆ្នាំ២០១៨ តិចជាងឆ្នាំ២០១៤, ២០១៥ និងឆ្នាំ២០១៧ តែច្រើនជាងឆ្នាំ២០១៦។

## II. លទ្ធផលអនុវត្តការងារតាមនាយកដ្ឋាន

## ១. នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ

### ១.១ ការងារបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

មកដល់ពេលនេះ អគ្គនាយកដ្ឋានកសិកម្មមានមន្ត្រីរាជការសរុបចំនួន ៥៧៨នាក់ ក្នុងនោះស្ត្រី១៦៩នាក់ ស្មើនឹង២៩,២៣% និងតាមក្របខ័ណ្ឌ "ក" មានចំនួន៣៥១នាក់ ក្នុងនោះស្រី៨៨នាក់ ក្របខ័ណ្ឌ "ខ" មានចំនួន១៣០នាក់ ក្នុងនោះស្ត្រី ៤៤នាក់ និងក្របខ័ណ្ឌ "គ" មានចំនួន៩៧នាក់ ក្នុងនោះស្ត្រី៣៧នាក់។ នៅក្នុងខែមេសានេះ អគ្គនាយកដ្ឋានកសិកម្មមានមន្ត្រីផ្ទេរចូលចំនួន០៣នាក់ មន្ត្រីនៅក្របខណ្ឌដើមចំនួន០៣នាក់ លុបឈ្មោះមន្ត្រីចំនួន០១នាក់ និងបានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ០២នាក់។

### ១.២ ការងារផែនការ និងស្ថិតិ

- ធ្វើរបាយការណ៍ប្រចាំថ្ងៃ សប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាសទី១ ស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨ និងការងារប្រមូលផលស្រូវ រដូវប្រាំងឆ្នាំ២០១៧-២០១៨
- ចុះតាមដាន និងវាយតម្លៃការអនុវត្តថវិកាតាមកម្មវិធីនៅខេត្តសៀមរាប
- រៀបចំរបាយការណ៍វឌ្ឍនភាពទម្រង់M1ត្រីមាសទី១
- រៀបចំរបាយការណ៍ ស្តីពីសកម្មភាពអនុវត្តការងារប្រចាំខែ របស់អគ្គនាយកដ្ឋានកសិកម្ម។

### ១.៣ ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- ទទួលពិនិត្យឯកសារទូទាត់ថវិកាកម្មវិធីជុំទី១ និងពិនិត្យបែបបទស្នើសុំថវិកាបេសកកម្មជូនបណ្តានាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- រៀបចំឯកសារស្នើសុំធានាចំណាយសម្រាប់អនុវត្តនីតិវិធីលទ្ធកម្ម
- រៀបចំកំណត់ត្រាចំណូលចំណាយរបស់អគ្គនាយកដ្ឋានកសិកម្ម
- បង្វែរប្រាក់បេសកកម្មជូនមន្ត្រីរាជការ។

### ១.៤ ការងារសហប្រតិបត្តិការអន្តរជាតិ និងសម្របសម្រួលគម្រោង

បានរៀបចំលិខិតសុំគោលការណ៍ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកសិកម្ម និង មន្ត្រីអគ្គនាយកដ្ឋានចូលរួមសិក្ខាសាលា កិច្ចប្រជុំ សន្និសិទ្ និងទស្សនៈកិច្ចទៅក្រៅប្រទេសចំនួន១៥នាក់ (ស្ត្រី០១នាក់)។

នៃឃុំចែងមានជ័យ ស្រុកបាណន់ [illegible] ស្វាយស ភូមិសម្តេច នៃឃុំតាប៉ុន ភូមិអំបែងថ្ងៃ ភូមិរកា នៃឃុំរកា ភូមិព្រៃចែក ភូមិក្រឡាញ់ ភូមិកំពង់ព្រះ ភូមិស្រះកែវ នៃឃុំកំពង់ព្រះ ភូមិអូរសទូក ភូមិសំបុកអក ភូមិសាលាត្រាវ ភូមិថ្មី នៃឃុំកំពង់ព្រៀង ភូមិវត្តកណ្ដាល ភូមិទួលស្នួល នៃឃុំរាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង។

ជាលទ្ធផលស្រុកបាណន់ និងស្រុកសង្កែ ខេត្តបាត់ដំបង ក្រុមការងារបានធ្វើការសន្និដ្ឋានដូចខាងក្រោមៈ

- ដីវាលស្មៅមួយចំនួនបានប្រែក្លាយទៅជាដីវាលស្រែ ស្រែប្រាំង និងភូមិប្រជាជន
- ដីព្រៃល្បោះ មួយចំនួន ក្លាយជាដីវាលស្រែ និងភូមិប្រជាជន
- ដីព្រៃល្បោះមួយចំនួនបានប្រែក្លាយជាដីចំការ
- ដីចំការដំណាំមួយចំនួន នៅជាដីចំការដំណាំដដែល
- ដីព្រៃលិចទឹកមួយចំនួនក្លាយជាដីស្រែប្រាំង
- ដីស្មៅបណ្ដែតទឹកមួយចំនួនក្លាយជាដីភូមិប្រជាជន
- ដីស្រែប្រាំងមួយចំនួនក្លាយជាដីស្រែ ។

**គ. គម្រោងការសិក្សាអង្កេត និងចាត់ថ្នាក់ដីកសិកម្ម**

បានចុះអង្កេតដី ពិពណ៌នាលក្ខណៈរូបរបស់ដី និងចាត់ថ្នាក់ក្រុមដីចំនួន០២លើក នៅឃុំចំនួន០១ និងភូមិចំនួន០៨ (ឃុំទ្រា ភូមិក្ដុលលើ ភូមិក្ដុលក្រោម ភូមិក្ដុលកណ្ដាល ភូមិទ្រាទី១ ភូមិទ្រាទី២ ភូមិទ្រាទី៣ ភូមិទ្រាទី៤ និងភូមិទ្រាទី៥)ស្ថិតនៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ សរុបលទ្ធផលខួងដីបានចំនួន១៥ចំណុចដែលមានដីចំនួន០៣ប្រភេទចាត់ថ្នាក់តាមប្រព័ន្ធ FAO/UNENSCO,(1989 ) គឺ៖ Eutric Fluvesols, Dystric Gleysols និង Eutric Cambisols។

**ឃ. គម្រោងបណ្ដុះបណ្ដាលស្ដីពីការវាយតម្លៃអំពីអត្តសញ្ញាណ និងចាត់ថ្នាក់ដីសម្រាប់ដាំដំណាំស្រូវនៅកម្ពុជាៈ**

បានរៀបចំផែនការចុះបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីការវាយតម្លៃនិងចាត់ថ្នាក់ដីសម្រាប់ដាំដុះដំណាំស្រូវនៅកម្ពុជា នៅខេត្តកំពង់ឆ្នាំង ចំនួន១វគ្គ ដែលមានអ្នកចូលរួម មន្ត្រីចំនួន ២០នាក់ មកពីការិយាល័យកសិកម្មស្រុក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ង. គម្រោងសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មអភិរក្ស**

បានចុះពិនិត្យ និងតាមដានចំការបង្ហាញពីបច្ចេកទេសដាំដុះដោយមិនភ្ជួរនៅភូមិរស្មីសង្ហា ភូមិពេជ្រសង្វារ ឃុំរស្មីសង្ហា ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចំនួន១៥កន្លែង។

**ច. គម្រោងការគ្រប់គ្រងដីជាតិដីលើដំណាំចម្ការ**

បានបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីការគ្រប់គ្រងដីជាតិដីលើដំណាំចំការ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចំនួន១វគ្គ ដែលមានអ្នកចូលរួម ២៥នាក់ មន្ត្រីមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ឆ. គម្រោងសិក្សាពីជម្រើសបច្ចេកទេសសមស្របលើការគ្រប់គ្រងទឹក និងដីកសិកម្មសម្រាប់និរន្តភាពផលិតកម្មដំណាំដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖

បានចុះបណ្តុះបណ្តាលកសិករស្តីពីការគ្រប់គ្រងទឹក និងដីលើដំណាំកសិកម្ម ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ នៅភូមិថ្មី ឃុំតាគ្រាម ស្រុកបាណន់ ខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន ២៥រូប (ស្ត្រី ១៧ រូប) និង ភូមិដំណាក់គី ឃុំជើងគ្រាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង មានអ្នកចូលរួមចំនួន ២៥រូប (ស្ត្រី ១៦រូប)។

ជ. គម្រោងរៀបចំសេចក្តីព្រាងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់តំបន់កសិកម្ម

បន្តចុះប្រមូលព័ត៌មានស្តីពីលក្ខណៈវិនិច្ឆ័យក្នុងការកំណត់តំបន់កសិកម្ម នៅខេត្តរតនៈគីរី និងបានប្រជុំក្រុមការងារចំនួន០២ លើក ដែលមានអ្នកចូលរួម ៥០ នាក់ នៅអគ្គនាយកដ្ឋានកសិកម្ម។

២.២ ការងារសហការជាមួយដៃគូពាក់ព័ន្ធ

ក. ការងារដីសម្បទានសេដ្ឋកិច្ច

បន្តសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនដីសម្បទានដីសេដ្ឋកិច្ចនៅខេត្តកំពត កោះកុង ព្រះសីហនុ ក្រចេះ និងកំពង់ស្ពឺ។

ខ. ការងារសហការជាមួយមជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស(CASC)៖

- បានកំពុងតាមដាន និងត្រួតពិនិត្យការលូតលាស់របស់ដំណាំគម្របដីមានដូចជា Pearl Millet Sunhemp និងSorghum នៅចម្ការពិសោធន៍បង្ហាញស្ថិតនៅភូមិបរិបូណ៌ ឃុំស្ពៅ ស្រុករតនៈមណ្ឌល ដំណាំគម្របដីចំរុះរួមមាន Stylosanthes guianensis millet sunhemp Crotalaria ochroleuca និង Centrosema pascuorum នៅស្រែពិសោធន៍បង្ហាញនៅភូមិក្រពើកើត ឃុំក្រពើ ស្រុកបាណន់។
- បានកំពុងតាមដាន និងត្រួតពិនិត្យការលូតលាស់របស់ដំណាំគម្របដីមានដូចជា Pearl Millet Sunhemp Pigeon Pea និង Stylosanthes guianensis នៅចម្ការពិសោធន៍ ស្រុកចម្ការលើ ខេត្តកំពង់ចាម និងបានប្រមូលផល សំរាំងគ្រាប់ពូជដំណាំគម្របដីសំខាន់ៗរួមមាន៖ Sorghum ចំនួន ១.០១៥គ.ក្រ, millet ចំនួន ៤១៥គ.ក្រ, Sunnhemp ចំនួន ៥១២គ.ក្រ និងCrotalaria ochroleuca ចំនួន ៥០០គ.ក្រ សំរាប់ចែកជូនកសិករដែលសហការអនុវត្តការដាំដុះតាមបច្ចេកទេសកសិកម្មអភិរក្សជាមួយមជ្ឈមណ្ឌល
- បានកំពុងតាមដាន និងត្រួតពិនិត្យការលូតលាស់របស់ដំណាំគម្របដី Stylosanthes guianensis និង Centrosema pascuorum និងដំណាំសំរាប់បង្កើនប្រាក់ចំណូលក្រៅពីស្រូវរួមមាន ពោតស ត្រាវ សណ្តែកបាយ ល្ង សណ្តែកអង្គុយ នៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ស្រុកសន្ទុក ខេត្តកំពង់ធំ។

## ៣. នាយកដ្ឋានដំណាំស្រូវ

៣.១ លទ្ធផលការងារ

- បានចុះជ្រើសរើសទីតាំងរៀបចំវេទិកា និងទស្សនកិច្ចសិក្សាក្នុងខេត្តពោធិ៍សាត់ និងសៀមរាប
- បានប្រជុំពិភាក្សាពីគោលការណ៍ណែនាំ រៀបចំមេរៀនសំខាន់ៗ សម្រាប់ត្រៀមរៀបចំបើកវគ្គពង្រឹងបច្ចេកទេសវិធានការចម្រុះគ្រប់គ្រងដំណាំស្រូវដល់គ្រូបង្គោលតាមបណ្តាខេត្តគោលដៅ
- បានទំនាក់ទំនងជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តគោលដៅទាំង ៥ ដែលក្នុងនោះ មានខេត្តតាកែវ ព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង និងខេត្តបាត់ដំបង ដើម្បីសហការអនុវត្តការបណ្តុះបណ្តាលស្តីពីវិធានការចម្រុះគ្រប់គ្រងលើដំណាំស្រូវ និងបានកំណត់ទីកន្លែងសម្រាប់ដំណើរការសាលារៀនស្រែកសិករឆ្នាំ២០១៨នេះ
- បានជ្រើសរើសទីតាំងធ្វើបង្ហាញបានត្រឹមត្រូវទៅតាមគោលការណ៍ណែនាំ ហើយកសិករសហការណ៍បានចាប់ផ្តើមរៀបចំដី ដើម្បីធ្វើការដាំដុះដំណាំបង្ហាញបានរួចរាល់ដូចជា ដំណាំពោត ត្រសក់ និងឪឡឹក

- បានចុះត្រួតពិនិត្យ និងចូលរួមប្រមូលព័ត៌មានទាក់ទងចំនួន ម៉ាស៊ីនកិនស្រូវ ឡសម្ងួត និងឃ្លាំងស្តុកទុកស្រូវនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត កណ្តាល កំពង់ចាម និងខេត្តព្រៃវែង
- បានចុះពិភាក្សាផែនការសកម្មភាពជាមួយមន្ត្រីសហការ សម្រាប់ការបន្សុទ្ធពូជ(ការស្តារឡើងវិញ)នូវពូជស្រូវសំខាន់ៗដែរមានសក្តានុពលនៅក្នុងតំបន់ នៅខេត្តគោលដៅចំនួន០២គឺ ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង
- បានចុះជ្រើសរើសទីតាំង មន្ត្រីសហការ និងពិភាក្សាលើការងារ លើគម្រោងផលិតកម្ម និងជម្រុញការលក់គ្រាប់ពូជស្រូវល្អក្នុងកសិដ្ឋានផលិតពូជស្រូវទួលសំរោង ខេត្តបាត់ដំបង

៣.២ ការងារសហប្រតិបត្តិការ

- **គម្រោង ផលិតកម្ម និងជំរុញការប្រើប្រាស់គ្រាប់ពូជស្រូវ PRPP ក្រោមការជួយឧបត្ថម្ភថវិកាពី JICA ៖** បានចុះសាកសួរអំពីខ្សែសង្វាក់ផលិតកម្មគ្រាប់ពូជស្រូវ និងតំរូវការទីផ្សារខេត្តបាត់ដំបង កំពង់ឆ្នាំង តាកែវ និងខេត្តព្រៃវែង។បានចុះត្រួតពិនិត្យ និងតាមដានស្រែបង្ហាញ(ពូជស្រូវខា១៥)១កន្លែងនៅខេត្តបាត់ដំបង សម្រាប់ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសផលិតពូជស្រូវ(ដំណាក់កាលទី៣)។
- **គម្រោង ASTV របស់ IRRI ក្រោមការជួយឧបត្ថម្ភថវិកាពី USAID ៖** បានកំពុងដំណើរការធ្វើបង្ហាញផលិតកម្មគ្រាប់ពូជស្រូវខា១៥ សរុបចំនួន ៨០កន្លែង នៅក្នុងខេត្តគោលដៅ ចំនួន៤ គឺខេត្តពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។
- **កម្មវិធី CAVAC៖** ធ្វើបង្ហាញវាយតម្លៃស្រឡាយពូជស្រូវសែនក្រអូបបន្សាំនៅលើស្រែកសិករ ចំនួន២០បង្ហាញ នៅក្នុងខេត្តគោលដៅចំនួន០២គឺ ខេត្តព្រៃវែង ១០បង្ហាញ និងខេត្តតាកែវចំនួន១០បង្ហាញ និងបានប្រមូលផលរួចរាល់។ ដោយជោគជ័យក្នុងការធ្វើបង្ហាញវាយតម្លៃស្រឡាយពូជស្រូវសែនក្រអូបនៅក្នុងត្រីមាសទីពីរនេះ កម្មវិធីCAVAC ក៏បានបន្ថែមនូវខេត្តចំនួន៥ទៀត ហើយក្នុង១ខេត្តមាន៥បង្ហាញ ដោយប្រើប្រាស់ពូជខា១៥។

៣.៣ អង្គភាពក្រោមឱវាទនាយកដ្ឋានដំណាំស្រូវ

- **មណ្ឌលអភិវឌ្ឍន៍កសិកម្មទន្លេបាទី៖** ប្រមូលផលស្រូវសែនក្រអូបលើផ្ទៃដីទំហំ៧ហិកតា ។ បានធ្វើពិសោធន៍ស្តីពីការត្រួតពិនិត្យកាកសំណល់ Tricyclazol នៅក្នុងគ្រាប់ស្រូវ និងកែឆ្នៃសម្អាតគ្រាប់ស្រូវ (Monitoring Tricyclazol Residues in Rice Grains and polished Rice Grains)។ បានប្រមូលផល និងស្រង់ទិន្នន័យពិសោធន៍បង្ហាញប្រៀបធៀបពូជស្រូវក្រអូបចំនួន៣កន្លែង លើស្រែកសិករ នៅភូមិតាំងឫស្សី, ឃ្លាំងសម្បត្តិ និងភូមិចំបក់ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ។
- **មណ្ឌលពិសោធន៍កសិកម្មព្រៃផ្តៅ៖** បានធ្វើពិសោធន៍ស្តីពីការប្រើប្រាស់ថ្នាំកម្ចាត់ស្មៅលើស្រូវពង្រោះលើផ្ទៃដី០១ ហិកតា ស្រែបង្ហាញពង្រោះពូជស្រូវសែនក្រអូប លើផ្ទៃដី ០២ហិកតា និងស្រែបង្ហាញពីការស្ទូងពូជស្រូវសែនក្រអូប លើផ្ទៃដី០២ ហិកតា ស្ថិតក្នុងដំណាក់កាលលូតលាស់បែកគុម្ព។

## ៤. នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៤.១ សកម្មភាពការងារតាមការិយាល័យ

- ចុះត្រួតពិនិត្យនិងវាយតម្លៃក្រុមកសិករផលិតបន្លែសុវត្ថិភាពរបស់គម្រោងជម្រុញផលិតកម្មស្បៀងនៅខេត្តកំពង់ធំ សៀមរាប និងខេត្តពោធិ៍សាត់ ចាប់ពីថ្ងៃទី០២-០៦ ខែមេសា ឆ្នាំ២០១៨ និងខេត្តកំពង់ចាម និងខេត្តព្រៃវែងចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨
- ចុះពិនិត្យការងារផលិតកម្មពូជដំណាំបន្លែ នៅស្ថានីយ៍ក្បាលកោះ
- បានជ្រើសរើសកសិករ ដើម្បីចូលរួមអនុវត្តន៍ Organic នៅខេត្តកំពង់ចាម ចាប់ពីថ្ងៃទី០៣ ខែមេសា ដល់ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨

- រៀបចំឯកសារបច្ចេកទេសដាំដុះដំណាំស្វាយ ទុរេន ក្រូច សម្រាប់បង្រៀនកសិករក្នុងខេត្តគោលដៅគម្រោងថវិកាកម្មវិធី
- ចូលរួមរៀបចំសិក្ខាសាលាស្តីពីការផ្តល់ព័ត៌មាននិងប្រមូលទិន្នន័យសម្រាប់ព្រៀងស្តង់ដារស្វាយកែវរមៀត
- បានចូលរួមប្រជុំជាមួយធានាគារអភិវឌ្ឍន៍ជនបទ នៅនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ
- ចុះអនុវត្តក្នុងគម្រោង ស្តីពី ការអនុវត្តន៍កសិកម្មល្អលើដំណាំបន្លែ នៅខេត្តសៀមរាប និងខេត្តកំពង់ធំ ចាប់ពីថ្ងៃទី០៣ ខែមេសា ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨
- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្មបន្លែសរីរាង្គ នៅខេត្តកំពង់ចាម ចាប់ពីថ្ងៃទី០៩ ខែមេសា ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨
- បានចុះបើកវគ្គបណ្តុះបណ្តាល និងរៀបចំស្រែបង្ហាញ ស្តីពីបច្ចេកទេសក្រោយការប្រមូលផលនៅខេត្តកំពង់ធំ ចាប់ពីថ្ងៃទី០៩ ខែមេសា ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨
- ចុះប្រមូលផលពូជដំណាំសាកវប្បកម្មនៅខេត្តព្រៃវែង ចាប់ពីថ្ងៃទី០២ ខែមេសា ដល់ថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៨។

### ៤.២ សកម្មភាពការងារតាមស្ថានីយ និងមណ្ឌលអភិវឌ្ឍន៍ក្រោមឱវាទនាយកដ្ឋាន

#### ក. ស្ថានីយពិសោធន៍ដំណាំហូបផ្លែ និងរុក្ខជាតិលម្អ ដីតដុះ

➢ បានពិសោធន៍ស្រាវជ្រាវ អភិរក្ស និងពង្រីកពូជដំណាំ រុក្ខជាតិលម្អ និងដំណាំហូបផ្លែចំនួន ១៣មុខ លើផ្ទៃដី០២ហិកតា។

*តារាង៖ ការងារដាំអភិរក្សនិងពង្រីកពូជដំណាំ*

| លេខរៀង | មុខដំណាំ | ខ្នាត | បរិមាណ | សំគាល់ |
|---|---|---|---|---|
| 1 | ស្រកានាគ | ដើម | 100 | ពិសោធន៍ |
| 2 | ផ្កាត្រីហ្សង់តែម | ដើម | 10,000 | ពិសោធន៍ |
| 3 | ផ្កាស្បៃរឿង | ដើម | 1,000 | ពិសោធន៍ |
| 4 | ស្លាលម្អ | ដើម | 1,000 | ពិសោធន៍ |
| 5 | ដូងតាំង | ដើម | 700 | ពិសោធន៍ |
| 6 | អន្សៃ | ដើម | 1,500 | ពិសោធន៍ |
| 7 | ម្ទេសលម្អ | ដើម | 2,000 | ពិសោធន៍ |
| 8 | គល់ទំសេរម្រាប់ស្វាយ៦ពូជ | ដើម | 600 | ពិសោធន៍ |
| 9 | កុតស(រុក្ខជាតិលម្អ) | ដើម | 200 | ពិសោធន៍ |
| 10 | ស្វាយកែវចិន | ហិកតា | 0.5 | ពិសោធន៍ |
| 11 | ល្ហុង | ហិកតា | 0.5 | ពិសោធន៍ |
| 12 | សាលាដខ្មែរ+អឺរ៉ុប | ហិកតា | 1.0 | ពិសោធន៍ |
| 13 | សណ្តែកទ្រើង | ហិកតា | 1.0 | ពិសោធន៍ |

➢ **ផ្នែកផលិតកម្ម** ៖ ផ្ទៃដីសរុប ៣ហិកតា ក្នុងនោះបានដាំដុះ និងថែទាំដំណាំដូចខាងក្រោម ៖

| ល.រ | មុខដំណាំ | ផ្ទៃដី(ម²) |
|---|---|---|
| 1 | សណ្តែកកួរ | 1,000 |
| 2 | សណ្តែកបាយ | 800 |
| 3 | ស្ពៃខៀវ | 800 |
| 4 | ស្ពៃចង្កឹះ | 600 |
| 5 | ប៉េងប៉ោះផ្លែធំ៦ពូជ | 1,200 |
| 6 | ប៉េងប៉ោះផ្លែតូច៤ពូជ | 800 |
| 7 | ត្រប់វែង | 800 |
| 8 | ត្រប់ខ្លី | 800 |
| 9 | ពោតដំណើប | 1,000 |
| | | សរុប=7,800 ម² |

## ខ. ស្ថានីយពិសោធន៍ពូជបន្លែក្បាលកោះ៖

*តារាង៖ ដំណាំដែលបានដាំដុះ និងថែទាំ*

| ល.រ | មុខដំណាំ | ផ្ទៃដី(ម៉ែត្រការ៉េ) | ផ្សេងៗ |
|---|---|---|---|
| 1 | សណ្តែកកួរ១ពូជ | 1,000 | |
| 2 | សណ្តែកបាយ២ពូជ | 800 | ធ្វើការប្រមូលផល |
| 3 | ស្ពៃខៀវ១ពូជ | 800 | ធ្វើការប្រមូលផល |
| 4 | ស្ពៃចង្កឹះ១ពូជ | 600 | ធ្វើការប្រមូលផល |
| 5 | ប៉េងប៉ោះផ្លែធំ ៦ពូជ | 1,200 | |
| 6 | ប៉េងប៉ោះផ្លែតូច ៤ពូជ | 800 | |
| 7 | ត្រប់វែង១ពូជ | 800 | |
| 8 | ត្រប់ខ្លី១ពូជ | 800 | |
| 9 | ពោតដំណើប១ពូជ | 1,500 | |
| 10 | ពោតផ្អែម១ពូជ | 1,000 | |
| 11 | ខ្ទឹមបារាំង១ពូជ | 20 | សាកល្បង |
| 12 | ការ៉ុត១ពូជ | 20 | សាកល្បង |
| សរុប | | 9,340 | |

## គ. មជ្ឈមណ្ឌលអភិវឌ្ឍន៍ពិពិធកម្មដំណាំកប់ស្រូវ៖

- បន្តធ្វើការសហការណ៍ជាមួយគម្រោងCAPROCសម្រាប់ក្នុងការបណ្តុះបណ្តាលកសិករក្នុងគម្រោងចំនួន៨ខេត្ត និងពិសោធន៍ដាំដំណាំបន្លែលើផ្ទៃដី៥.៨៥៦ម៉ែត្រការ៉េ
- ពិសោធន៍ដាំដុះស្រូវលើផ្ទៃដី៥.០០០ម៉ែត្រការ៉េ ចំនួន៣៦ពូជ
- ថែទាំដំណាំរួមផ្សំ ដើមស្វាយ និងដើមមៀនក្នុងគោលបំណងពិសោធន៍និងផ្សាំមែក និងដាំដុះដំណាំបន្លែចំរុះជាលក្ខណៈសរីរាង្គ យកស្លឹកនិងផ្លែដូចជា៖ សណ្តែកកួរ និងស្ពៃខៀវលើផ្ទៃដី១៥០ម២
- បណ្តុះកូនខ្នុរ១០០០កូន សម្រាប់ដាំដុះក្នុងមណ្ឌលនិងចែកជូនកសិករក្នុងតំបន់គោលដៅ។

# ៥. នាយកដ្ឋានដំណាំឧស្សាហកម្ម

### ៥.១ លទ្ធផលការងារតាមការិយាល័យ

- ចុះអនុវត្តសកម្មភាពការងារគម្រោងតាមថវិកាកម្មវិធី នៅខេត្តកណ្តាល និងខេត្តកំពង់ចាម
- រៀបចំប្រមូលទិន្នន័យ ព័ត៌មាន និងស្ថិតិដំណាំពាក់ព័ន្ធនានា ពីបណ្តាខេត្តគោលដៅ ដើម្បីរៀបចំ និងចងក្រងសម្រាប់រៀបចំផែនការសកម្មភាព
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវតម្លៃខ្សែសង្វាក់ផលិតកម្ម ដំណាំដំឡូងមី ម្រេច របស់គម្រោងជម្រុញផលិតកម្មស្បៀងនៅថ្ងៃទី០៤-០៥ ខែមេសា ឆ្នាំ២០១៧
- ចូលរួមធ្វើទិវាបង្ហាញពីដំណាំពោត នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ប្រជុំណែនាំធ្វើផែនការការងារពិសោធន៍នៅ ខេត្តតាកែវ ព្រះសីហនុ កំពង់ចាម និងខេត្តកណ្តាល
- ដាំរក្សាពូជពោតឡើងវិញ ដើម្បីបន្សុទ្ធ និងបង្កាត់រកពូជពោតអ៊ីប្រ៊ីតចំនួន១៩០ស្រទ្បាយ ស្ថិតនៅក្នុងដំណាក់កាលប្រមូលផល និងហាលសម្ងួត
- ដាំជ្រើសរើសឯកត្តៈពូជពោតអ៊ីប្រ៊ីតថ្មីពីស្រទ្បាយ៨៤ស្រទ្បាយ ស្ថិតក្នុងដំណាក់កាលដាក់គ្រាប់ ទុំ និងត្រៀមប្រមូលផល
- ដាំផលិតពូជពោតអ៊ីប្រ៊ីត (៣:១) ជ្រើសរើសពីមេបាពូជ ៥០០៦៦ និង៥០០៥៦ ក្នុងដំណាក់កាលទុំ និងត្រៀមប្រមូលផល។

៥.២ ការងារពិសោធន៍នៅតាមស្ថានីយ និងកសិដ្ឋាន នៅក្រោមឱវាទ

**ក. ស្ថានីយពិសោធន៍កសិកម្មបន្ទាយដែក**

- ពិសោធន៍វាយតម្លៃទិន្នផលពូជពោតអ៊ីប្រ៊ីតចំនួន ៨ពូជ ក្នុងដំណាក់កាលដាក់គ្រាប់
- ដាំរក្សាពូជពោតក្រហមចំនួន ០៥ពូជ ស្ថិតក្នុងដំណាក់កាលប្រមូលផល ពូជពោតដំណើប ០១ពូជ ស្ថិតក្នុងដំណាក់កាលចេញផ្កា និងបន្តដាំរក្សាពូជពោតស OPV បាន០១ពូជទៀតបានប្រមូលផលរួច
- ដាំបន្សុទ្ធពូជសណ្តែកបាយ ១ពូជ (BD-17) ស្ថិតក្នុងដំណាក់កាលកំពុងប្រមូលផល, ពូជពោតក្រហម ១ពូជ (SBD-8-2) ស្ថិតក្នុងដំណាក់កាលដាក់គ្រាប់ និងពូជពោតសចំណីសត្វ ១ពូជ (SBD-HS) ស្ថិតក្នុងដំណាក់កាលចេញផ្កា
- ពិសោធន៍ប្រៀបធៀបពូជដំណាំមនចំនួន១១ពូជ និងរៀបចំសមូហកម្មពូជមនថ្មី២៧ពូជ
- ផលិតកម្មដំណាំពោតក្រហមចំណីសត្វLVN១០ បានចំនួន ១,៣០ហិកតា និងដំណាំសណ្តែកបាយចំនួន ១,២០ហិកតា បានប្រមូលផលរួចហើយ
- បានចិញ្ចឹមដង្កូវនាងចំនួន៦ពូជគឺ ពូជដង្កូវនាងខេត្តតាកែវ, Gold Silk, ពូជខ្មែរ, ពូជCK1.7.1, ពូជ CK1.7.3 និងពូជ CK1.7.4។

**ខ. ស្ថានីយពិសោធន៍កសិកម្មវាលរេញ**

- ថែទាំដំណាំម្រេចចំនួន៣០០ជន្លង់
- ថែទាំអភិរក្សពូជស្វាយចន្ទីចំនួន ០២ពូជ។

## ៦. នាយកដ្ឋានវិស្វកម្មកសិកម្ម

៦.១ ការងារសិក្សាស្រាវជ្រាវ និងសាកពិសោធន៍

**ក. ការងារចងក្រងឯកសារមេរៀន៖**

១/ រចនាផ្ទាំងរូបភាព ស្តីពីការកែសម្រួលស៊ូប៉ាប់របស់ចលករ ២/ ស្រាវជ្រាវចងក្រងមេរៀនបច្ចេកទេសស្តីពីការត្រួតពិនិត្យកែសម្រួលនិងជួសជុលចលករសាំង ៣/ ចងក្រងអត្ថបទបច្ចេកទេសបីផ្គត់ ស្តីពីលក្ខណៈទូទៅរបស់ធុងទឹកនិងគម្របធុងទឹកចលករ ៤/ ចងក្រងមេរៀន ស្តីពីតម្រូវការទឹករបស់ជំឡុងបារាំង និងកែសម្រួលមេរៀនស្តីពីឧបករណ៍ដាំស្រូវបំពាក់ដោយគោយន្តនិងត្រាក់ទ័រ និងកែសម្រួលមេរៀន ការកៀរពង្រាបដីដោយឡាហ្វៃចំណុចមធ្យម កៀរចេញ និងកៀរចូលតាមតារាង Excel ។

**ខ. ការងារគូរប្លង់ឧបករណ៍កសិកម្ម៖**

បន្តកែសម្រួលគំនូរប្លង់ឧបករណ៍ដាំស្រូវ ប្លង់ម៉ាស៊ីនធ្វើស្មៅក្នុងស្រែ កែសម្រួលប្លង់ឡាហ្វៃរ បន្តសិក្សាស្រាវជ្រាវគូរប្លង់ឧបករណ៍ជ្រួយដី រចនាប្លង់ធុងប្រអប់ត្រជាក់ (Cool Box)សម្រាប់ដាក់បន្លែផ្លែឈើ ឱ្យបានយូរ ដោយប្រើកម្មវិធី Solidwork និងបន្តស្រាវជ្រាវបច្ចេកទេសរចនាប្លង់នៃឧបករណ៍ផ្សេងៗ ដោយប្រើកម្មវិធី Solidwork ។

**គ.ការងារបច្ចេកទេស៖**

បន្តការផលិតឧបករណ៍ដាំគ្រាប់ស្រូវបំពាក់ពីក្រោយគោយន្ត០១គ្រឿង។ បានរៀបចំត្រាក់ទ័រ និងឧបកណ៍ ៣ក់ សម្រាប់ត្រៀមចុះអនុវត្តការងារតាមកម្មវិធីឆ្នាំ២០១៨ និងបានពិនិត្យ ថែទាំគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្មដែលរក្សាទុកក្នុងឃ្លាំងតាមបទដ្ឋានបច្ចេកទេស។

៦.២ ការងារពិសោធន៍ និងអនុវត្តបង្ហាញ

- បានធ្វើការសាកពិសោធន៍បាចដីដោយម៉ាស៊ីនព្រោះស្រូវ នៅនាយកដ្ឋានវិស្វកម្មកសិកម្ម និងនៅទំនប់កប់ស្រូវ និងសាកពិសោធន៍ឧបករណ៍រៀបចំដីគំរូថ្មី និងសាកពិសោធន៍ឧបករណ៍កសិកម្ម នៅខេត្តតាកែវ និងខេត្តកំពង់ធំ

- បានចុះអនុវត្តបង្ហាញបច្ចេកទេសស្រោចស្រពតំណក់ទឹកលើដំណាំកសិកម្ម នៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ
- បានធ្វើបង្ហាញ ស្តីពីការស្វែងយល់ពីអត្ថប្រយោជន៍ នៃការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ នៅសហគមន៍មរតកបន្សាយត្រែង ស្រុកថ្មគោល ខេត្តបាត់ដំបង
- បានចុះអនុវត្តបង្ហាញបច្ចេកទេសរៀបចំដីដោយគ្រឿងយន្តកសិកម្ម នៅខេត្តស្វាយរៀង
- បានចុះពង្រឹង និងគាំទ្រសេវាបច្ចេកទេសកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែរ នៅខេត្តព្រៃវែង កំពង់ធំ និងខេត្តបាត់ដំបង និងពិនិត្យទីតាំងអនុវត្តន៍កែលម្អប្រព័ន្ធដីស្រែចំការ នៅខេត្តកំពង់ឆ្នាំង។

## ៧. នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

### ៧.១ ការស្រាវជ្រាវ និងអនុវត្តបច្ចេកទេស

- បន្តរៀបចំគម្រោងដើម្បីដាក់ស្នើសុំទៅដៃគូអភិវឌ្ឍនានា ក្នុងការអនុវត្តការងារ លិខិតបទដ្ឋានទាំងផ្នែកធនធានមនុស្ស ឧបករណ៍សម្ភារៈ និងប្រព័ន្ធផ្លាស់ប្តូរព័ត៌មានលើការងារអនុវត្តកសិកម្មល្អ (GAP)
- បន្តចុះតាមដានស្ថានីយ៍ពិសោធន៍ដំណាំឈើហូបផ្លែ និងរុក្ខជាតិលម្អដីឥដ្ឋ ដើម្បីក្លាយជាស្ថានីយ៍នៃការអនុវត្ត កសិកម្មល្អកម្ពុជា ដែលបានឯកភាពពីឯឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មកាលពីថ្ងៃ ទី២២ ខែកុម្ភៈ ឆ្នាំ២០១៨កន្លងមកនេះ។ ជាលទ្ធផលស្ថានីយ៍កំពុងធ្វើការកែសម្រួលទៅតាមការណែនាំបច្ចេកទេសនៃការអនុវត្តកសិកម្មល្អកម្ពុជាពីមន្ត្រីជំនាញដែលចុះវាយតម្លៃ
- ពិសោធន៍ជីវប្រសិទ្ធិភាពថ្នាំកសិកម្មនៅទីវាលបានចំនួន០៧មុខ ដែលរួមមាន៖ ថ្នាំកម្ចាត់សត្វល្អិតចំនួន ០២មុខ ថ្នាំកម្ចាត់ជំងឺផ្សិតចំនួន ០៣មុខ និងថ្នាំកម្ចាត់ស្មៅចង្រៃចំនួន ០២មុខ ។

### ៧.២ ការងារសម្របសម្រួលការនាំចេញផលិតផលកសិកម្ម និងការនាំចូល

#### ក. ការងារត្រួតពិនិត្យភូតគាមអនាម័យលើផលិតផលនាំចេញនៅការិយាល័យកណ្តាល

មកដល់ខែមេសាឆ្នាំ២០១៨ នេះការិយាល័យភូតគាមអនាម័យនៃនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាម អនាម័យបានធ្វើការត្រួតពិនិត្យភូតគាមអនាម័យកសិផលកម្ពុជានាំចេញ និងផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យបានចំនួន ១.៧៦០ច្បាប់ (គិតត្រឹមថ្ងៃ ទី២០ ខែមេសា ឆ្នាំ២០១៨)។

*តារាងឈ្មោះ និងបរិមាណផលិតផលនាំចេញ*

| ល.រ | ប្រភេទកសិផល | ឈ្មោះជាភាសាអង់គ្លេស | បរិមាណសរុប (តោន) | ប្រទេសនាំចូល |
|---|---|---|---|---|
| ១ | អង្ករ | Rice | 77,587.44<br>គិតត្រឹមថ្ងៃទី២០ខែមេសា ឆ្នាំ២០១៨ | AUSTRALIA,AUSTRIA,BELGUIM,BISSAU, BULGARIA,BRUNEI DARUSALAM, CANADA,CHINA, CYPRUS,CZECH REPUBLIC,DENMARK,FINLAND, FRANCE,IVORY COAST,GABON,GERMANY,HONG KONG, HONGARY,ITALY,LATVIA,LITHUNIA,LEBANON,MACAU,MALTA,MAYLAYSIA,MAYOTTE,NAMIBIA, NETHERLANDS, NEWZEALAND,POLAND, PORTUGAL,RUSSIAN FEDERATION, SINGAPORE,SLOVENIA,SPAIN,SWEDEN, TURKEY,THAILAND,UNITED KINGDOM, UNITED STATES, UKRIANE, VEITNAM |
| ២ | ចំណិតដំឡូងមី | Cassava slice | 104,590.00 | VEITNAM,THAILAND |
| ៣ | ដំឡូងមីស្រស់ | Fresh manioc | 22,550.00 | VIETNAM, THAILAND |
| ៤ | ម្សៅដំឡូងមី | Cassava starch | 9,221.60 | CHINA,THAILAND,VIETNAM |
| ៥ | កាកសំណល់ដំឡូងមី | Cassava residue | 2,743.06 | CHINA,VEITNAM |
| ៦ | ផ្លែដូងប្រេង | Palm kernel/Crude Palm oil | 12,700.00 | MALAYSIA,CHINA,SWITZERLAND |

| | | | | |
|---|---|---|---|---|
| ៧ | ជ័រកៅស៊ូ | Natural rubber | 2,096.55 | ITALY, CHINA, VIETNAM, INDIA,MALAYSIA |
| ៨ | សសៃគុយទាវ/មីសួរ/មី | Rick Stick/noodle | 289.809 | AUSTRLIA, CZECH REPUBLIC,DENMARK,FINLAND,IRELAND, GERMANY,NETHERLAND,SWEDEN, NEWZEALAND,UNITEDKINGDOM,FRANCE |
| ៩ | ឈើកៅស៊ូកែច្នៃ | Process rubber wood | 2,886.957 | VEITNAM |
| ១០ | ម្រេច | Black Pepper | 129.04 | VEITNAM,GERMANY,JAPAN, FRANCE,ISRAEL,PORTUGAL, AUSTRALIA,RUSSIAN FEDERATION |
| ១១ | ផ្លែស្វាយស្រស់ | Fresh fruit Mango | 21,514.71 | HONG KONG,VEITNAM,THAILAND, FRANCE,RUSSIAN FEDERATION |
| ១២ | ពោត | Corn | 26,192.02 | KOREA,TAIWAN,VIETNAM,THAILAND |
| ១៣ | ម្ទេសស្រស់ | Fresh chilly | 4,650.00 | VIETNAM,THAILAND |
| ១៤ | ដំណាប់ស្វាយ | Dried mango | 20.22 | JAPAN,VEITNAM,CHINA |
| ១៥ | ឈើកែច្នៃ | Process wood | 2,473.69 | VEITNAM,KOREA |
| ១៦ | កាកស្រាបៀរ | Spent yeast | 117.00 | USA |
| ១៧ | ម្សៅចំណីសត្វ | Meat and bone meal | 305.50 | VEITNAM |
| ១៨ | គ្រាប់ស្វាយចន្ទី | Cashew nut | 29,183.84 | VEITNAM,INDIA,THAILAND |
| ១៩ | ផ្លែចេកស្រស់ | Fresh Banana | 2,553.586 | KOREA,VIETNAM |
| ២០ | រមៀត | Dried finger turmeric | 57.00 | INDIA |
| ២១ | ទឹកស៊ីរ៉ូស្វាយ | Mango preserved | 616.72 | PHILIPPINE |
| ២២ | គ្រាប់សណ្តែកក្តាយ | Sachainchi nut | 14.71 | KOREA |
| ២៣ | ថ្នាំជក់ | Tobacco | 529.807 | VEITNAM,HUNGARY,INDIA, GERMANY,USA,BULGARIA |
| ២៤ | ម្សៅកាកាវ | Cacao powder | 331.50 | CHINA |
| ២៥ | ដំឡូងជ្វា | Sweet potato | 1,100.00 | THAILAND |
| ២៦ | ស្ករត្នោត | Palm sugar | 27.28 | SPAIN,NETHERLAND |
| ២៧ | គ្រាប់ខ្វែរ | Mucuna planting seed | 7.00 | NIGERIA |
| ២៨ | ផ្សិត | Mushroom | 0.75 | KOREA |
| ២៩ | ម្សៅធូបមូស | Charcoal powder | 50.682 | CHINA |
| ៣០ | ស្លឹកតេជ្រូម | Bay leaf | 0.06 | USA |
| ៣១ | ម្សៅម្រុំ | Moringa powder | 2.97 | USA,FRANCE |
| ៣២ | ម្សៅ ញ | Noni powder/noni dried | 1.90 | KOREA |
| ៣៣ | ផ្លែម្នាស់ | Pineapple | 0.13 | KOREA |
| ៣៤ | ស្ករអំពៅ | Cane sugar | 38,150.00 | CHINA |
| ៣៥ | សំបកពពួលបាយ | Per sea kurzi slice | 3.00 | THAILAND |
| ៣៦ | ផ្លែស្រកានាគ | Dragon fruit | 60.00 | VIETNAM |
| ៣៧ | កន្ទេលកក់ | Red mat | 1,000.00 | THAILAND |
| ៣៨ | ល្ង | Sesame | 7.14 | TAIWAN |
| ៣៩ | បន្លែនិងផ្លែឈើគ្រប់ប្រភេទ | Vegetable & fruits | 16.55 | CZECH REPUBLIC, UNITED KINGDOM,FRANCE |
| សរុប | | | 363,782.22 តោន | |

## ខ. ការងារត្រួតពិនិត្យភូតគាមអនាម័យលើផលិតផលនាំចូលនៅការិយាល័យកណ្តាល

*តារាងឈ្មោះ និងបរិមាណផលិតផលនាំចូល*

| ល.រ | ប្រភេទកសិផល | ឈ្មោះជាភាសាអង់គ្លេស | បរិមាណសរុប(តោន) | ប្រទេសនាំចេញ |
|---|---|---|---|---|
| ១ | ផ្លែសាឡាក់ | Salacca | 7.50 | INDONESIA |
| ២ | ផ្លែចេក | Banana | 3.71 | CHINA |
| ៣ | សណ្តែកបាយ | Mungbean | 0.05 | AUSTRALIA |
| ៤ | រុក្ខជាតិលំអ | Live oak | 32.69 | CHINA |

| | | | | |
|---|---|---|---|---|
| ៥ | ដើមមន | Morusnigra | 14.54 | CHINA |
| ៦ | ម្រុំ | Moringa | 2.50 | INDIA |
| សរុប | | | 60.99 តោន | |

**គ. ស្នាក់ការត្រួតពិនិត្យភូតគាមអនាម័យប្រចាំស្នាក់ការច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

➢ **ការនាំចេញ៖**

- បានត្រួតពិនិត្យបន្លែ ផ្លែឈើនាំចេញរបស់ក្រុមហ៊ុន Soun Thong Import Export CO.,LTD ទៅកាន់ប្រទេសបារាំងចំនួន ១២.៩៤៣គីឡូក្រាម ដែលមានចំនួន០៩ វិញ្ញាបនបត្រ បានត្រួតពិនិត្យបន្លែនាំចេញរបស់ក្រុមហ៊ុន D.U sevice Co.Ltd ទៅកាន់ប្រទេស United Kingdom និងCzech Republic ចំនួន ៣.១៨០ គីឡូក្រាម ដែលមានចំនួន ១១ វិញ្ញាបនបត្រ និងបន្លែនាំចេញរបស់ក្រុមហ៊ុន SomNog Import Export CO.,LTD ទៅកាន់ប្រទេសកូរ៉េ ចំនួន ១,១៨៦ គីឡូក្រាម ដែលមានចំនួន ០១វិញ្ញាបនបត្រ
- ត្រួតពិនិត្យផ្លែស្វាយនាំចេញរបស់ក្រុមហ៊ុន Kingdom Fruits International CO.,LTD ទៅកាន់ប្រទេសបារាំងនិង Russian Federation ចំនួន ៧.០០៧ គីឡូក្រាម ដែលមានចំនួន០២វិញ្ញាបនបត្រ
- បានត្រួតពិនិត្យម្រេចនាំចេញរបស់ក្រុមហ៊ុន WELLER TRANSPORT & IMPORT EXPORT CO.,LTD ទៅកាន់ប្រទេសKoreaចំនួន ៥,០០០ គីឡូក្រាម ដែលមានចំនួន ០១វិញ្ញាបនបត្រ។

➢ **ការនាំចូល៖** បានត្រួតពិនិត្យផ្លែសាឡាក់របស់ក្រុមហ៊ុន SALAK K A K TRADING Co.,LTD ចំនួន ៣០.៤៣២ គ.ក្រ និងត្រួតពិនិត្យផ្លែសាលាក់ របស់ក្រុមហ៊ុនCHHEN DE IMPORT Co.,LTD ចំនួន០៤លើក ដែលមានបរិមាណទំនិញចំនួន ៨.៨៧០គ.ក្រ។ បានត្រួតពិនិត្យកូនចេករបស់ក្រុមហ៊ុន LONGMATE AGRICULTURE Co.,LTD ចំនួន០២លើកដែលមានបរិមាណទំនិញចំនួន ៤.០៣៨,៥០ គីឡូក្រាម។

៧.៣ គម្រោងសហការ

**ក. គម្រោង ADB Loan No. 2873-CAM (SF)៖**

ចុះប្រមូលសំណាកជំងឺវីរុស ជំងឺបាក់តេរី និងណេម៉ាតូតលើដំណាំពោត កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨ នៅខេត្តកណ្តាល។ សំណាកដែលប្រមូលបានទាំងអស់មាន ៤៨សំណាក ហើយយើងបានកំពុងបណ្តុះមេរោគ និងរក្សាទុកបណ្តើៗ ដើម្បីរង់ចាំអ្នកជំនាញការមកធ្វើការកំណត់អត្តសញ្ញាណកម្ម។

**ខ. សហការជាមួយគម្រោង TCP/CMB/3604 ស្តីពី Strengthening Capacity in Managing the incursion of Cassava Mosaic Virus infestation in Cambodia**

បានកំពុងធ្វើការវិភាគសំណាកជំងឺវីរុសលើដំឡូងមី ដែលប្រមូលបានមកពីខេត្តរតនៈគិរី និងខេត្តត្បូងឃ្មុំ និងកំពុងរៀបចំផែនការ និងអនុវត្តសាលារៀនស្រែកសិករ នៅខេត្តរតនគីរី ក្រចេះ និងខេត្តត្បូងឃ្មុំ ដើម្បីបញ្ជ្រាបការយល់ដឹងដល់កសិករពីផលប៉ះពាល់នៃជំងឺCMD ។

**គ. គម្រោង Asian Food and Agriculture Cooperation Initiative (AFACI)/Korea ក្នុងការ Development of Guideline for Specific Crop on GAP and Produce Safety Information System in Cambodia**

កំពុងបន្តកែសម្រួលឯកសារបច្ចេកទេសផ្នែកគុណភាពផលិតផល រៀបចំ Poster ស្តីពីការអនុវត្តកសិកម្មល្អ និងរៀបចំឯកសារនៃការធ្វើសវនកម្ម និងរៀបចំទម្រង់ Check List of Specific crop នៃការអនុវត្តកសិកម្មល្អ។

៧.៦ ការងារនៅស្ថានីយ៍ពិសោធន៍ការពារដំណាំពោធិ៍លាស់

ធ្វើពិសោធន៍តាមដានពីហានិភ័យនៃសមាសភាពចង្រៃលើដំណាំសណ្តែកសៀង និងដំណាំដំឡូងបារាំង នៅក្នុងផ្ទះកញ្ចក់។ បានសហការជាមួយនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ និងនាយកដ្ឋានដំណាំស្រូវ ពិសោធន៍ស្រាវជ្រាវពីថ្នាំកសិកម្មទ្រីស៊ីក្លាសូលលើពូជស្រូវ ខា១៤។

## ៨. នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

### ៨.១ ការងារបណ្តុះបណ្តាល និងសិក្ខាសាលា

- ចូលរួមក្នុងពិធីចែកវិញ្ញាប័នបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនសម្បទាននិក និងសម្ពោធសមិទ្ធផល នានាក្នុងទីតាំងសម្បទានដីសង្គមកិច្ច របស់គម្រោងបែងចែកដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំហានទី២ (LASEDII) ស្ថិតក្នុងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី ២៨ ដល់ ២៩ ខែ មីនា ឆ្នាំ២០១៨
- ចុះប្រមូលព័ត៌មាន នៃការចងក្រងបណ្ណាញការសិក្សាពីកសិករទៅកសិករ លើកការរៀបចំលក្ខន្តិកៈ មជ្ឈមណ្ឌលសិក្សាសហគមន៍កម្មវិធី ASPIRE នៅខេត្តកណ្តាល និងខេត្តតាកែវ នាថ្ងៃទី ០៣-០៥ ខែមេសា ឆ្នាំ២០១៨
- ប្រជុំពិនិត្យគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ដែលមានអ្នកចូលរួមសរុបចំនួន ១៥នាក់ ក្នុងនោះស្ត្រីចំនួន ០៣នាក់ នៅសាលប្រជុំនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- សិក្ខាសាលាស្តីពីគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ដែលមានអ្នកចូលរួមសរុបចំនួន ៤៩នាក់ ក្នុងនោះស្ត្រីចំនួន ១២នាក់ នៅអគ្គនាយកដ្ឋានកសិកម្ម
- ប្រជុំពិនិត្យឡើងវិញពីគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ដែលមានអ្នកចូលរួមសរុបចំនួន ០៧នាក់ ក្នុងនោះស្ត្រីចំនួន ០៣នាក់ នៅសាលប្រជុំនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

### ៨.២ ការសម្របសម្រួលសេវាផ្សព្វផ្សាយកសិកម្ម

**ក. ការងារផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ (ទូរទស្សន៍)**

- បានរៀបចំផលិតជាឯកសារ និងផ្សព្វផ្សាយតាមកម្មវិធីទូរទស្សន៍ជាតិកម្ពុជានូវ **នាទីកសិកម្មប្រចាំសប្តាហ៍** ចំនួន ០១ឯកសារ ស្មើនឹង៨ដង ដូចជាកម្មវិធីចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ដំណាំម្រេះ ការចិញ្ចឹមជ្រូក និងប្រព័ន្ធកសិកម្មចម្រុះ
- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជារៀបចំផលិតឯកសារវេទិកាស្វែងយល់ពីកសិកម្ម និងចាក់ផ្សាយតាមកម្មវិធីរបស់ទូរទស្សន៍ជាតិជារៀងរាល់ថ្ងៃអង្គារវេលាម៉ោង៥:៣០ល្ងាច មានចំនួន០១ឯកសារ ស្មើនឹង ៤ដង ពីនីតិវិធីនៃការផ្តល់បញ្ជីការ លិខិតអនុញ្ញាតិនាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងការធ្វើអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម
- ផលិតឯកសារចុះស្រែជាមួយកសិករ និងចាក់ផ្សាយតាមកម្មវិធីរបស់ទូរទស្សន៍ជាតិជារៀងរាល់ថ្ងៃច័ន្ទ វេលាម៉ោង៥:៣០ល្ងាច ដែលមានព័ត៌មានចំនួន ០១ឯកសារ ស្មើនឹង៤ដង លើដំណាំសណ្តែកបាយ
- បានផ្សព្វផ្សាយព័ត៌មានកសិកម្មតាមស្ថានីយ៍ទូរទស្សន៍បានចំនួន ១៤ព័ត៌មាន។

**ខ. ការផលិត និងផ្សព្វផ្សាយតាមវិទ្យុជាតិ**

បានរៀបចំឯកសារ និងចាក់ផ្សាយអត្ថបទខ្សែអាត់បច្ចេកទេសនៅស្ថានីយវិទ្យុជាតិ FM105.70.75MHz ចំនួន០២ថ្ងៃក្នុងមួយសប្តាហ៍(ថ្ងៃច័ន្ទ និងថ្ងៃព្រហស្បតិ៍ចាប់ពីម៉ោង៩:០០នាទី ដល់ម៉ោង៩:៣០នាទីព្រឹក ចំនួន៨ដង ដែលមានប្រធានបទចំនួន៣ដូចជា៖ ដំណាំខាត់ណា ដំណាំននោង និងការរៀបចំទ្រុងសម្រាប់ចិញ្ចឹមមាន់។

**គ. ការងារបោះពុម្ពផ្សាយ**

- រៀបចំបោះពុម្ពកូនសៀវភៅបច្ចេកទេសបន្លែខ្ទឹមបារាំង និងការ៉ុត បច្ចេកទេសដំណាំសណ្តែកសៀង និងបច្ចេកទេសការទុកដាក់ដំណាំបន្លែក្រោយប្រមូលផល
- រៀបចំព្រឹត្តិប័តការចិញ្ចឹមត្រីក្នុងស្រែជាលក្ខណៈគ្រួសារ
- រៀបចំបោះពុម្ពទស្សនាវដ្តីត្រីមាសទី១ និងរៀបចំទស្សនាវដ្តីប្រចាំត្រីមាសទី២ ឆ្នាំ២០១៨

៨.៣ គម្រោងសហការ

ក. **កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)**

ប្រជុំពិភាក្សាពីការណែនាំនិងអនុវត្តកិច្ចសន្យាជួលអ្នកខាងក្រៅកាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៨ នៅសាលប្រជុំនាយកដ្ឋានផ្សព្វផ្សាយដែលមានអ្នកចូលរួម ៨នាក់ ស្រី៣នាក់។

**ខ. គម្រោងជម្រុញផលិតកម្មស្បៀង**

- ធ្វើការផ្សព្វផ្សាយអំពីគម្រោងជំរុញផលិតកម្មស្បៀងតាម Facebook និង គេហទំព័រគម្រោង
- ដឹកនាំថតវីដេអូ ស្តីពីបន្លែសុវត្ថិភាពរបស់គម្រោងជម្រុញផលិតកម្មស្បៀងចាប់ពីថ្ងៃទី ២៦ ដល់ ៣០ ខែមីនា ឆ្នាំ២០១៨ នៅខេត្តព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ធំ
- ចុះពិនិត្យទីតាំងថតវីដេអូ អំពីការផលិតពូជស្រូវនៅតាមសហគមន៍ របស់គម្រោងជម្រុញផលិតកម្មស្បៀង នៅខេត្តព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ធំ នាថ្ងៃទី០៣-០៧ ខែមេសា ឆ្នាំ២០១៨។

**គ. គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចដំណាក់កាលពីរ (LASEDII)**

- រៀបចំកិច្ចប្រជុំបច្ចេកទេសកសិកម្ម នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង ដែលមានអ្នកចូលរួមសរុបចំនួន៣០នាក់ ស្ត្រី០៦នាក់
- ចូលរួមប្រជុំបង្ហាញផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ របស់គម្រោង LASED II ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តម អៀង វុធ អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង
- បានសហការណ៍ជាមួយមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ចុះយកសំណាក វិភាគគុណភាពដីចំនួន ០៦សំណាក នៅតំបន់ដីសម្បទានសង្គមកិច្ច ឃុំដូង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

## ៩. នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

៩.១ សកម្មភាពការងារ

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ ក្រោមអធិបតីភាពលោក អ៊ុក ស៊ីផាន អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម ដែលមានអ្នកចូលរួមសរុប៥២នាក់ ក្នុងនោះស្ត្រី១០នាក់ នៅសាលប្រជុំអគ្គនាយកដ្ឋានកសិកម្ម
- បានប្រជុំត្រួតពិនិត្យ និងយោបល់លើប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគមន៍កសិកម្ម (AC Database System) ដល់ថ្នាក់ដឹកនាំនាយកដ្ឋាន និងថ្នាក់ដឹកនាំការិយាល័យ ដែលមានអ្នកចូលរួមសរុប៥នាក់ ក្នុងនោះស្ត្រី ២នាក់ នៅសាលប្រជុំនាយកដ្ឋាន
- ចូលរួមប្រជុំពិភាក្សាលើការរៀបចំពិពណ៌ផលិតផលកសិកម្មក្នុងពិធីច្រត់ព្រះនង្គ័លឆ្នាំ២០១៨ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រជុំផ្សព្វផ្សាយគ្រូបង្គោលស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍កសិកម្ម ដែលមានអ្នកចូលរួមសរុប៥០នាក់ ក្នុងនោះ១០នាក់ នៅខេត្តកំពង់ឆ្នាំង
- ចុះតាមដានសកម្មភាពផ្សព្វផ្សាយក្រុមលម្អទុនបង្វិល(IGR Fs)ទៅជាសហគមន៍កសិកម្ម នៅខេត្តកំពត
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី នីតិវិធីនៃការរៀបចំ និងការបង្កើតសហគមន៍កសិកម្មដល់មន្ត្រីតាមដាន និងវាយតម្លៃថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ នៅខេត្តកណ្តាល
- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការរៀបចំផ្សព្វផ្សាយបង្កើតសហគមន៍កសិកម្ម និងផ្សព្វផ្សាយសហភាពកសិកម្ម នៃក្រុមកែលម្អទុនបង្វិល (IGR Fs) ដល់មន្ត្រីថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ ដែលមានអ្នកចូលរួមសរុប ៤២នាក់ ក្នុងនោះស្ត្រី១៦នាក់ នៅខេត្តព្រៃវែង។

៩.២ គម្រោងសហការ

**ក. គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)៖**

- ចុះតាមដានការអនុវត្តមុខជំនួញសាកល្បងរបស់សហគមន៍កសិកម្មល្អសមាស សហគមន៍កសិកម្មស្ទឹងស្លាគូ និងសហគមន៍កសិកម្មជើងគួនជោគជ័យ ក្នុងខេត្តតាកែវ
- ចុះតាមដានការអនុវត្តផែនការមុខជំនួញរបស់សហគមន៍កសិកម្មដែលគម្រោងជ្រើសរើសដើម្បីអនុវត្តមុខជំនួញសាកល្បងគឺសហគមន៍កសិកម្មសំបូរមានជ័យនៅខេត្តកំពង់ចាម ដោយមានការចូលរួមពីមន្ត្រីការិយាល័យសហគមន៍កសិកម្មចំនួន២រូប និងកសិករ៥រូប
- បានបញ្ចប់ឯកសារបណ្តុះបណ្តាលសម្រាប់សហគមន៍កសិកម្ម ស្តីការចុះបញ្ជីគណនេយ្យសម្រាប់សហគមន៍កសិកម្ម
- បាននិងកំពុងត្រួតពិនិត្យរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់សហគមន៍កសិកម្មទាំងអស់ក្នុងខេត្តគោលដៅរបស់គម្រោង
- ចុះតាមដានផែនការមុខរបរសហគមន៍កសិកម្មស្គរឆ្មោតខេត្តកំពង់ស្ពឺ និងមុខរបរឥណទានសហគមន៍កសិកម្មជម្រុះទិទាន ក្នុងខេត្តកំពង់ស្ពឺ ។

**ខ. គម្រោងជម្រុញផលិតកម្មស្បៀង(BFP)**

- បានចូលរួមត្រួតពិនិត្យ និងវាយតម្លៃក្រុមកសិករផលិតកម្មបន្លែសុវត្ថិភាពឆ្នាំ២០១៨ នៅក្នុងខេត្តព្រៃវែង កណ្តាល និងខេត្តត្បូងឃ្មុំ
- បានពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង នៃពាក្យស្នើសុំចុះឈ្មោះជាកសិករដាំបន្លែសុវត្ថិភាព។

## ១០. មន្ទីរពិសោធន៍ជាតិកសិកម្ម

- ចំណូលសេវាសាធារណៈក្នុងខែមេសា ឆ្នាំ២០១៨ បានចំនួន ៥៤.៧៨១.០០០ រៀល
- ចុះយកសំណាកបន្លែ ផ្លែឈើ ថ្នាំកសិកម្ម និងរុក្ខជាតិតាមបណ្តាខេត្តគោលដៅចំនួន១០ ដើម្បីយកមកវិភាគតាមជំនាញនីមួយៗនៃគម្រោងថវិកាតាមកម្មវិធី
- វិភាគដីបានចំនួន ៦១សំណាក និងវិភាគជីបានចំនួន ៣៤សំណាក សម្រាប់សេវាសាធារណៈ និងវិភាគរុក្ខជាតិបានចំនួន ០១សំណាក
- វិភាគគុណភាពថ្នាំកសិកម្មនៃសេវាសាធារណៈបានចំនួន ៤៣សំណាក និងវិភាគក្នុងគម្រោង(P3-P4) បានចំនួន ៧០សំណាក ក្នុងនោះវិភាគគុណភាពថ្នាំកសិកម្ម ៣០សំណាក និងបន្លែផ្លែឈើ ៤០សំណាក
- ធ្វើតេស្តដំណុះគ្រាប់ពូជពោតក្រហម ពោតស និងដំណាំសណ្តែកខៀវបានចំនួន ២០សំណាក និងចុះយកសំណាកគ្រាប់ពូជបានចំនួន ១០សំណាក ក្នុងខេត្តចំនួន០៤ សម្រាប់គម្រោងថវិកាកម្មវិធី ។

## III. ទិសដៅអនុវត្តការងារបន្ត

- សិក្សាស្រាវជ្រាវពីស្ថានភាពទូទៅនៃដំណាំឧស្សាហកម្ម បច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ជំរុញការងារផលិតពូជ និងពន្យូទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ និងរៀបចំចងក្រងឯកសារបច្ចេកទេសផ្សេងៗដែលពាក់ព័ន្ធនឹងដំណាំឧស្សាហកម្ម
- បន្តជំរុញការងារផ្សព្វផ្សាយពូជដំណាំឧស្សាហកម្មសំខាន់ៗដូចជា ពោត ដំឡូងឈើ សណ្តែក ស្វាយចន្ទី។ល។ តាមរយៈការធ្វើបង្ហាញ និងទិវាចម្ការអោយបានទូលំទូលាយ
- បន្តស្រាវជ្រាវ ផលិតកែច្នៃ និងសាកពិសោធន៍លើការងារគ្រឿងយន្តកសិកម្ម ការកែច្នៃក្រោយប្រមូលផល ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដីស្រែ ប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក លើដំណាំ និងប្រព័ន្ធប្រឡាយជើងក្អែប
- រៀបចំសៀវភៅបណ្តុះបណ្តាលគោលការណ៍ណែនាំនិងខិតប័ណ្ណសម្រាប់ឱ្យការិយាល័យសហគមន៍

កសិកម្មរាជធានី-ខេត្ត និងសហគមន៍កសិកម្មប្រើប្រាស់

- ពង្រឹងការងារត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ និងតាមតម្រូវការនៃប្រទេសនាំចូលក្នុងគោលបំណងជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា
- បន្តស្រាវជ្រាវឯកសារបច្ចេកទេស និងរៀបចំជាសៀវភៅបច្ចេកទេសសម្រាប់មន្ត្រី និងកសិករ និងអប់រំផ្សព្វផ្សាយបច្ចេកទេសជូនដល់ប្រជាកសិករស្តីពី វិធីសាស្ត្រក្នុងការការពារ និងការកម្ចាត់សមាសភាពចង្រៃផ្សេងៗលើផលិតកម្មកសិកម្ម
- បន្តរៀបចំផែនការពីជម្រើសបច្ចេកទេសសមស្របលើការគ្រប់គ្រងទឹក និងដីកសិកម្មសម្រាប់និរន្តភាពផលិតកម្មដំណាំដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ចុះរៀបចំគោលការណ៍ណែនាំការងារផ្សព្វផ្សាយកសិកម្មរបស់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្មនៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តពោធិ៍សាត់
- អនុវត្តសកម្មភាពថវិកាឆ្នាំ២០១៨ បន្តទៀតលើការពង្រឹងសមត្ថភាព និងគាំទ្រសេវាផ្សព្វផ្សាយកសិកម្ម លើផ្នែកសិក្សា និងវិភាគប្រព័ន្ធកសិកម្ម និងផ្នែកសិក្សាវាយតម្លៃពីស្ថានភាពសេដ្ឋកិច្ចកសិកម្មរបស់គ្រួសារកសិករ

## IV. សន្និដ្ឋាន

របាយការណ៍នេះបានបង្ហាញពីលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី ថវិកាពីដៃគូអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធនានាក្នុងការរួមចំណែកជំរុញកំណើនផលិតកម្មដំណាំ ដើម្បីចូលរួមកាត់បន្ថយនូវភាពក្រីក្រ របស់ប្រជាពលរដ្ឋ តាមរយៈការសិក្សាពិសោធន៍ស្រាវជ្រាវបច្ចេកទេសថ្មីៗពាក់ព័ន្ធនឹងអនុវិស័យដំណាំការអភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការបណ្តុះបណ្តាលធនធានមនុស្ស ការបង្កើតនិងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងពិសេសសកម្មភាពអប់រំផ្សព្វផ្សាយបច្ចេកទេស។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានកសិកម្មបានជំរុញ និងខិតខំស្តារនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមស្ថានីយ កសិដ្ឋាន និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្មឱ្យមានភាពសំបូរបែប និងលទ្ធភាពគ្រប់គ្រាន់ក្នុងការពិសោធន៍ ស្រាវជ្រាវ និងអនុវត្តបង្ហាញព្រមទាំងផ្តល់លទ្ធភាពកាន់តែងាយស្រួលក្នុងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយក្តីអនុគ្រោះ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

<u>ចម្លងជូន</u>
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ-ស្ថិតិ
- គ្រប់នាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
  "ដើម្បីជ្រាប"
- ឯកសារកាលប្បវត្តិ